# ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ

## ចក្ខុវិស័យឆ្នាំ២០៣០

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

លេខ: ០០២ សសរ.

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្តាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល និងអភិបាលនៃគណៈអភិបាលក្រុងតាខ្មៅ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ......០០២ សសរ......ចុះថ្ងៃ......ព្រហស្បតិ៍ ៥កើត......ខែ......បឋមាសាឍ......ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី......០៥......ខែ......កក្កដា......ឆ្នាំ២០១៨

ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្ដាល

# ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ

## ចក្ខុវិស័យឆ្នាំ២០៣០

# មាតិកា

ទំព័រ

**១-សេចក្តីផ្តើម** ..... ៤

**២-ចក្ខុវិស័យ** ..... ៥

២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម ..... ៥

២.២-ចក្ខុវិស័យ ..... ៦

**៣-គោលបំណង និងគោលដៅ** ..... ៦

៣.១-គោលបំណង ..... ៦

៣.២-គោលដៅ ..... ៦

**៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សក្រុងតាខ្មៅ** ..... ៧

៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព ..... ៧

*៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម* ..... *៧*

*៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងការប្រើប្រាស់ដី* ..... *៩*

៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ ..... ១៤

*៤.២.១-តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង* ..... *១៥*

*៤.២.២-តំបន់ទេសចរណ៍ធម្មជាតិ* ..... *១៥*

*៤.២.៣-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍* ..... *១៦*

*៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស* ..... *១៧*

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម ..... ១៧

*៤.៣.១-អ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ភ្ជាប់ទៅអន្តរជាតិ* ..... *១៧*

*៤.៣.២-ផ្លូវថ្នល់* ..... *១៧*

*៤.៣.៣-ផ្លូវទឹក* ..... *១៨*

*៤.៣.៤-ផ្លូវអាកាស* ..... *១៨*

*៤.៣.៥-ថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា* ..... *១៩*

*៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌* ..... *១៩*

*៤.៣.៧-ការផ្គត់ផ្គង់ទឹកស្អាត* ..... *១៩*

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក ..... ២០

៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ..... ២១

៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ ..... ២១

*៤.៦.១-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង* ..... *២១*

*៤.៦.២-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ................................................ ២២*

*៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន................................................ ២២*

*៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ................................................ ២២*

៤.៧- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម................................................ ២៣

៤.៨- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម................................................ ២៣

៤.៩- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ................................................ ២៤

៤.១០- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន................................................ ២៤

**៥-ផែនការសកម្មភាព................................................ ២៥**

៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម................................................ ២៥

៥.២- ការផ្សព្វផ្សាយ................................................ ២៥

៥.៣- ការអនុវត្តគម្រោងតាមវិស័យ................................................ ២៥

*៥.៣.១-ការអភិវឌ្ឍក្រុង................................................ ២៥*

*៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍................................................ ២៦*

*៥.៣.៣-ការដឹកជញ្ជូន................................................ ២៦*

*៥.៣.៤-ការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម................................................ ២៦*

*៥.៣.៥-ការគ្រប់គ្រងបរិស្ថាន................................................ ២៧*

*៥.៣.៦-ការគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកស្អាត................................................ ២៧*

*៥.៣.៧-ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងសំណល់រាវ................................................ ២៧*

*៥.៣.៨-ការគ្រប់គ្រងសំណល់រឹង................................................ ២៧*

*៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍................................................ ២៨*

៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង................................................ ២៨

*៥.៤.១-ការអនុវត្តរយៈពេលខ្លី................................................ ២៨*

*៥.៤.២-ការអនុវត្តរយៈពេលមធ្យម................................................ ២៩*

*៥.៤.៣-ការអនុវត្តរយៈពេលវែង................................................ ៣០*

**៦-ធនធានហិរញ្ញវត្ថុ................................................ ៣២**

**៧-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ................................................ ៣២**

៧.១- យន្តការ................................................ ៣២

៧.២- ច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត................................................ ៣២

៧.៣-ភារកិច្ច នីតិវិធី គោលការណ៍................................................ ៣៣

**៨-សេចក្តីសន្និដ្ឋាន................................................ ៣៣**

**៩-អនុសាសន៍**........................................................................................................ ៣៤

**ឯកសារឧបសម្ព័ន្ធ**........................................................................................................ **៣៥**

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ក្រុងតាខ្មៅជាមជ្ឈមណ្ឌលសេដ្ឋកិច្ចស្នូល និងរស់រវើករបស់ខេត្តកណ្តាលដែលមានទំនាក់ទំនងដ៏ល្អប្រសើរជាមួយរាជធានីភ្នំពេញ គាំទ្រដល់ការរស់នៅ ការប្រកបការងារ និងការលម្ហែកម្សាន្ត។ លក្ខណៈពិសេសរបស់ក្រុងតាខ្មៅ មានភូមិសាស្ត្រជាប់នឹងរាជធានីភ្នំពេញ បានធ្វើឱ្យក្រុងតាខ្មៅមានអំណោយផលយ៉ាងល្អដល់ទំនាក់ទំនងសេដ្ឋកិច្ច សង្គមកិច្ច និងផ្តល់ការងារជាច្រើនសម្រាប់ប្រជាពលរដ្ឋ។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍន៍ក្រុងតាខ្មៅប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ខេត្តកណ្តាល និងក្រុងតាខ្មៅ ក្រោមការគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចក្ខុវិស័យឆ្នាំ២០៣០ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងតម្រង់ទិសអភិវឌ្ឍន៍ដែនដីក្រុងតាខ្មៅទាំងមូល ស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីនេះ ត្រូវបានកសាងឡើងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីនេះ មានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និង បច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដីការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្សទន្លេបាសាក់ ស្ទឹងព្រែកត្នោត និងបឹងធម្មជាតិជាច្រើន ដែលអាចទទួលផលប៉ះពាល់ដោយសារសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ឬដោយសារការប្រែប្រួលអាកាសធាតុ ដូចជា ការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅក្នុងទីក្រុង របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។

**២-ចក្ខុវិស័យ**

**២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម**

ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូល និងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច សង្គម បរិស្ថាន ប្រជាសាស្ត្រ និងការស្រង់មតិ ស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី (សៀវភៅ ស ដីធ្លី) និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ២០៣០ ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅត្រូវបានសិក្សាលើក្របខណ្ឌសេដ្ឋកិច្ច សង្គមដោយផ្អែកលើសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រនៃក្រុងតាខ្មៅ ក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ក្រុងតាខ្មៅបច្ចុប្បន្ន បូករួមទាំងបួនឃុំទៀតនៃស្រុកស្អាង មានឃុំរកាខ្ពស់ ឃុំសិត្បូ ឃុំកោះអន្លង់ចិន និងឃុំស្វាយរលំ និងឃុំជើងកើប ស្រុកកណ្តាលស្ទឹង គឺនៅឆ្នាំ២០០៨ មានប្រជាជនចំនួន១២៤ ៨៣១នាក់ នឹងកើនឡើងដល់២៦៩ ៩៦៣ នាក់ នៅឆ្នាំ២០៣០ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំទិន្នន័យជំរឿនទូទៅនៃប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និង ២០០៨។

ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុងតាខ្មៅនៅឆ្នាំ២០០៨ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមាន១១ ៧៦៨ នាក់ (១៨,៧៩%) ក្នុងវិស័យឧស្សាហកម្មមាន២៤ ២៤៣ នាក់ (៣៨,៧១%) និងក្នុងវិស័យសេវាកម្មមាន២៦ ៦១៣ នាក់ (៤២,៥០%) ហើយរំពឹងថានៅឆ្នាំ២០៣០ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមានការថយចុះមកត្រឹម៥ ២៩០ នាក់ (៣,៥០%) ក្នុងវិស័យឧស្សាហកម្មមានការកើនឡើងដល់ចំនួន៧៨ ៦១៣នាក់ (៥២%) និងក្នុងវិស័យសេវាកម្មមានការកើនឡើងដល់ចំនួន៦៧ ២៧៥ នាក់ (៤៤,៥០%)។

## ២.២- ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣០ នៃប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ គឺសំដៅដល់ការរៀបចំ និងអភិវឌ្ឍន៍ **"ក្រុងតាខ្មៅ ជាទីក្រុងពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ ដែលមានគុណភាពបរិស្ថាន និងការរស់នៅប្រកបដោយសុខដុមរមនា"** តាមរយៈការរៀបចំ និងជំរុញទៅជា៖ ១).ទីក្រុងមានសកម្មភាពពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគល្អប្រសើរ ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ២).ទីក្រុងអភិវឌ្ឍន៍ឧស្សាហកម្មទំនើប សិប្បកម្ម និងសហគ្រាសខ្នាតតូចនិងមធ្យម ដោយមានការទាក់ទាញការវិនិយោគ ធានាបាននូវកំណើនសេដ្ឋកិច្ច និងកំណើនការងារ ៣).ទីក្រុងទេសចរណ៍ដែលមានគុណភាព សេវាកម្ម ធានាបាននូវភាពទាក់ទាញ និងការចាប់អារម្មណ៍ខ្ពស់ពីភ្ញៀវជាតិ និងអន្តរជាតិ ៤).ទីក្រុងប្រកបដោយគុណភាពបរិស្ថាន និងការរស់នៅប្រកបដោយសុខដុមរមនា និង ៥).ទីក្រុងអភិរក្សធនធានធម្មជាតិ ទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងធម្មជាតិ និងតំបន់ធនធានទឹកជាច្រើន។

វិសាលភាពនៃការសិក្សាប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០ គឺមានការសិក្សាលើដែនកំណត់ព្រំប្រទល់រដ្ឋបាលក្រុងបច្ចុប្បន្នចំនួន៦សង្កាត់ បូករួមនឹងការពង្រីកបន្ថែម៤ ឃុំទៀត ស្ថិតក្នុងស្រុកស្អាង និងមួយផ្នែកទៀតនៃឃុំជើងកើបស្រុកកណ្តាលស្ទឹង ដែលធ្វើឱ្យក្រុងតាខ្មៅមានឃុំ សង្កាត់សរុបចំនួន ១០ និងមានទំហំផ្ទៃដីចំនួន ១១ ២១០,៦៧ ហិកតា។ ក្នុងនោះក្រុងតាខ្មៅបច្ចុប្បន្នមានចំនួន៦ សង្កាត់ (សង្កាត់តាក្តុល សង្កាត់ដើមមៀន សង្កាត់កំពង់សំណាញ់ សង្កាត់ព្រែកឫស្សី សង្កាត់ព្រែកហូរ និងសង្កាត់តាខ្មៅ) មានផ្ទៃដីសរុប ៣ ២២២,៣៦ ហិកតា បួនឃុំទៀតនៃស្រុកស្អាង (ឃុំរកាខ្ពស់ ឃុំសិត្បូ ឃុំកោះអន្លង់ចិន និងឃុំស្វាយរលំ) មានផ្ទៃដីសរុប៧ ៩៨៨,២៧ ហិកតា និងឃុំជើងកើប ស្រុកកណ្តាលស្ទឹង មានផ្ទៃដីសរុប១៩០,១៥ ហិកតា។

# ៣- គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ មានគោលបំណង និងគោលដៅដូចខាងក្រោម៖

## ៣.១- គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ មានគោលបំណងធានាការគ្រប់គ្រងដី ការប្រើប្រាស់ដី ការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព គុណភាព តុល្យភាព ចីរភាព និងសមធម៌។

## ៣.២- គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ មានគោលដៅ៖

- គ្រប់គ្រង ការពារ រៀបចំ ប្រើប្រាស់ អភិវឌ្ឍដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព សមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងការធានាសន្តិសុខស្បៀង

- ជំរុញកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍន៍ធុរកិច្ចទាក់ទាញ ដើម្បីគាំទ្រដល់ការវិនិយោគសាធារណៈ និងឯកជន
- គ្រប់គ្រងជីវវដ្ត ធនធានធម្មជាតិ បរិស្ថាន ជំរុញអភិវឌ្ឍន៍បៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយ
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាបានសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយ និងឆ្លើយតបបានល្អ តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទូទៅ និងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចទីក្រុង នៅក្នុងកម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សក្រុងតាខ្មៅ

ក្រុងតាខ្មៅ ជាមជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខេត្តកណ្តាលដែលមានភូមិសាស្ត្រនៅជាប់នឹងរាជធានីភ្នំពេញប៉ែកខាងត្បូង និងមានផ្លូវជាតិចំនួន៣ ឆ្លងកាត់គឺ ទី១).ផ្លូវជាតិលេខ២ កាត់តាមបណ្តោយក្រុងពីជើងទៅលិច តភ្ជាប់ពីរាជធានីភ្នំពេញ ទៅខេត្តតាកែវ ផ្លូវជាតិលេខ២១ ពីទីរួមខេត្តកណ្តាល ទៅស្រុកស្អាង និងស្រុកកោះធំ ទី២).ផ្លូវក្រវាត់រាជធានីភ្នំពេញទី២ កាត់តាមក្រុងតាខ្មៅតាមបណ្តោយផ្លូវ១១៥ ឆ្ពោះទៅផ្លូវជាតិលេខ១ ទី៣).ផ្លូវសម្តេចតេជោ ហ៊ុន សែន តភ្ជាប់ពីរាជធានីភ្នំពេញកាត់តាមផ្លូវជាតិលេខ២ និងតភ្ជាប់ជាមួយផ្លូវក្រវាត់ក្រុងតាខ្មៅទី១ កាត់តាមផ្លូវក្រវាត់ក្រុងទី៣ ផ្លូវជាតិលេខ២១ និងផ្លូវក្រវាត់ក្រុងតាខ្មៅទី២។ ក្រុងតាខ្មៅ មានទន្លេបាសាក់ធំធេងហូរកាត់លម្អខាងមុខក្រុង និងស្ទឹងព្រែកត្នោតស្រស់បំព្រង តភ្ជាប់ពីទន្លេបាសាក់ទៅខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នទីក្រុងតាខ្មៅមាន៦ សង្កាត់ (មិនទាន់ពង្រីកក្រុង) មានប្រជាជនសរុបចំនួន៧៦ ៧៣៣នាក់ (ឆ្នាំ២០១៥) និងដង់ស៊ីតេប្រជាជនស្មើនឹង២ ៣៨២ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។ ចំណែកឯក្រុងតាខ្មៅថ្មីមាន១០ ឃុំ សង្កាត់ (ពង្រីកក្រុងតាមរយៈគម្រោងប្លង់គោលប្រើប្រាស់ដីសម្រាប់ឆ្នាំ២០៣០) មានប្រជាជនសរុបចំនួន១២០ ២១៤ នាក់(ឆ្នាំ២០១៥) មានដង់ស៊ីតេប្រជាជនស្មើនឹង១ ០៧២ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច ការធ្វើសមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម៖

### ៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

#### ៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម

##### ក)-តំបន់ក្រុងបច្ចុប្បន្ន

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ជំរុញការដាក់លេខផ្ទះ ឈ្មោះផ្លូវនិងលេខផ្លូវ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង

- កែលម្អ និងស្តារបឹងរាន បឹងត្នោត បឹងទឹកជោរ សួនតាមមាត់ទន្លេបាសាក់ ផ្លូវ និងភ្លើងបំភ្លឺ ឱ្យមានសោភ័ណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់និងពេលថ្ងៃ
- កែលម្អ និងស្តារ ផ្លូវជាតិលេខ២១ ផ្លូវក្រវាត់រាជធានីភ្នំពេញ ផ្លូវក្រវាត់ក្រុងតាខ្មៅ និងនៅតាមចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើនិងដាំដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម ឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ គុណភាពបរិស្ថានល្អ
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លម្ហសាធារណៈ កំណត់ប្រភេទ និងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងតាខ្មៅស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាព រស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយផាសុកភាព សម្រាប់មនុស្សទាំងអស់គ្នា
- គ្រប់គ្រងអភិរក្សសំណង់បេតិកភណ្ឌសម័យបុរាណ ដោយរៀបចំបញ្ជីសារពើភ័ណ្ឌ ធ្វើចំណាត់ថ្នាក់សំណង់ស្ថាបត្យកម្មបុរាណ និងកំណត់វិធានការនិងបទប្បញ្ញត្តិ សម្រាប់ការគ្រប់គ្រង និងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព សុវត្ថិភាព សោភ័ណភាព សណ្តាប់ធ្នាប់ និង បរិស្ថានល្អ។ សំណង់បេតិកភណ្ឌសម័យបុរាណក្នុងក្រុងតាខ្មៅរួមមាន តំបន់ផ្សារតាខ្មៅចាស់ វត្តតាខ្មៅ វត្តព្រែកសំរោង វិហារចិន អគារនៅជាប់មន្ទីរពេទ្យជ័យជិនះ អគារនៅក្បែរមន្ទីរបក្សប្រជាជនកម្ពុជាខេត្ត ព្រមទាំងវត្តវិហារ សំណង់អគារ និងផ្ទះបុរាណមួយចំនួនទៀត ដែលជាទីកន្លែងកម្សាន្ត និងសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រដ៏មានប្រជាប្រិយភាពរបស់ក្រុង
- កំណត់តំបន់ដែលត្រូវរៀបចំកែលម្អទីក្រុង កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ មានផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹងនិងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅ និងសោភ័ណភាពក្រុង
- កំណត់តំបន់អភិវឌ្ឍន៍ទីក្រុងឡើងវិញ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ បង្កើនលទ្ធភាពនៃការប្រើប្រាស់ដី លើកកម្ពស់គុណភាពបរិស្ថាននៃការរស់នៅ និងទាក់ទាញការវិនិយោគ
- រៀបចំ និងកំណត់រចនាបថអគារ ពណ៌អគារ និងកំណត់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវនិងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ ស្របតាមទីតាំងភូមិសាស្ត្រ។

ខ)-ទិសដៅនគរូបនីយកម្ម

- ការអភិវឌ្ឍទីក្រុង និងនគរូបនីយកម្មមាននិន្នាការ និងពង្រីកឆ្ពោះទៅទិសខាងត្បូង និងទិសខាងកើតនៃទីក្រុងបច្ចុប្បន្ន ដោយការពារផ្ទៃដីសក្តានុពលកសិកម្មខ្ពស់ ការពារប្រភពទឹក និងអាងស្តុកទឹកធម្មជាតិ មានជាអាទិ៍ ទន្លេ ស្ទឹង ព្រែក ប្រឡាយ អូរ បឹង
- រៀបចំផែនការកំណត់កម្ពស់អគារ ទាប មធ្យម និងខ្ពស់ ក្នុងទីក្រុងបច្ចុប្បន្ន
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍរូបវន្ត ជាពិសេសបណ្តាញផ្លូវ ប្រព័ន្ធលូ អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមុន
- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការកសាងផែនការរូបវន្ត និងគ្រប់គ្រងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព ជាពិសេសមន្ត្រីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលជាសេនាធិការលើការងាររៀបចំដែនដី និងនគរូបនីយកម្ម។

### ៤.១.២- យុទ្ធសាស្ត្រគ្រប់គ្រង និងការប្រើប្រាស់ដី

ក្រុងតាខ្មៅមានផ្ទៃដីទំហំប្រមាណ១១ ២១០,៦៧ ហិកតា ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីកម្រិតការសាងសង់ និងប្រភេទដីអាចសាងសង់បាន។ បច្ចុប្បន្នការកម្រិតថ្នាក់ដីធ្លីនៃការសាងសង់ក្នុងក្រុងតាខ្មៅនៅមិនទាន់ត្រូវបានកំណត់ច្បាស់លាស់ក្នុងការអនុវត្តនៅឡើយ ជាពិសេស ដីធ្លីនៅតាមតំបន់ដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងទទឹងថ្ងៃ បឹងត្នោត បឹងរាន និងតំបន់ផ្ទៃទឹកមួយចំនួនទៀត។ ជាក់ស្តែងប្រភេទដីអាចសាងសង់បានគ្របដណ្តប់ស្ទើរគ្រប់ទីកន្លែងទាំងអស់ ក្នុងក្រុងតាខ្មៅទាំងមូល លើកលែងតែតំបន់កសិកម្ម និងផ្ទៃទឹកមួយចំនួន ដោយសារកង្វះខាតការរៀបចំក្រុង និងការអនុវត្តច្បាប់ ការតាមដានវាយតម្លៃការអនុវត្តច្បាប់ពាក់ព័ន្ធនៅមានកម្រិត។ សរុបសេចក្តីមក ការគ្រប់គ្រង និងការប្រើប្រាស់ដីបច្ចុប្បន្ននៅក្រុងតាខ្មៅពាក់ព័ន្ធនឹងការសាងសង់ គឺនៅមានភាពមិនច្បាស់លាស់ ដោយពុំទាន់មានបទប្បញ្ញត្តិណែនាំលម្អិតក្នុងការកំណត់ប្រភេទដីកម្រិតសាងសង់ និងអាចសាងសង់បាន ដើម្បីចាត់តាំងការអនុវត្តជាក់ស្តែងឱ្យមានប្រសិទ្ធភាពនៅឡើយ។ ជាមួយគ្នានេះ តាមរយៈការសិក្សាប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ឃើញថា នៅឆ្នាំ២០៣០ ប្រភេទដីកម្រិតការសាងសង់នឹងមានផ្ទៃដីប្រមាណ២ ៣៧១,១៣ ហិកតា ស្មើនឹង២១,១៥% ប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ៨ ៨៣៩,៥៤ ហិកតា ស្មើនឹង៧៨,៨៥%។

**ក)- ប្រភេទដីកម្រិតការសាងសង់**

ផ្អែកតាមអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីកាគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសលេខ៩៦១ សហវ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០ ស្តីពីការចុះអនុវត្តគោលការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវទូទាំងព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជាតំបន់ ដូចខាងក្រោម៖

**១-តំបន់កសិកម្ម៖** មានផ្ទៃដីប្រមាណ៥៩២,៧៧ ហិកតា ស្មើនឹង២៥,០០% មានទីតាំងជុំវិញបឹងរានមាន ស្ថិតនៅភូមិព្រែកឡុង និងភូមិព្រែកសំរោងនៃឃុំរកាខ្ពស់។

**២-តំបន់ព្រៃឈើ៖** មានផ្ទៃដីប្រមាណ៩៨,០២ ហិកតា ស្មើនឹង៤,១៣%។ ក្នុងនោះផ្ទៃដីប្រមាណ៧៧,៧៧ ហិកតា ស្ថិតនៅភូមិកោះគរ និងដីប្រមាណ២០,២៥ ហិកតា នៅជុំវិញបឹងរានក្នុងភូមិព្រែកឡុង និងភូមិព្រែកសំរោង នៃឃុំរកាខ្ពស់។

**៣-តំបន់ធនធានទឹក៖** មានផ្ទៃដីប្រមាណ១ ១៦៤,៣៩ ហិកតា ស្មើនឹង៤៩,១១% ដែលគ្របដណ្តប់ផ្នែកខ្លះនៃសង្កាត់ទាំង៥ ដែលតំបន់ផ្ទៃទឹកទាំងនោះរួមមានដូចជា៖

- ទន្លេបាសាក់មានផ្ទៃដីប្រមាណ៥៤១,៩០ ហិកតា
- បឹងត្នោតមានផ្ទៃដីប្រមាណ៧៩,០១ ហិកតា នៃផ្ទៃដីសរុបចុះបញ្ជី៨៣,៥៩ ហិកតា
- បឹងរានមានផ្ទៃដីប្រមាណ១០៩,៧២ ហិកតា នៃផ្ទៃដីសរុបចុះបញ្ជី១១០,៧១ ហិកតា
- បឹងទឹកជោមានផ្ទៃដីប្រមាណ១២,៧៧ ហិកតា នៃផ្ទៃដីសរុបចុះបញ្ជី១១,២១ ហិកតា
- បឹងទទឹងថ្ងៃមានផ្ទៃដីប្រមាណ៤១,៧០ ហិកតា នៃផ្ទៃដីសរុបចុះបញ្ជី៤១,០២ ហិកតា
- បឹងចាន់សារមានផ្ទៃដីប្រមាណ៣៥,៨៨ ហិកតា
- ស្ទឹងព្រែកហូរមានផ្ទៃដីប្រមាណ៣៣,៨២ ហិកតា
- ផ្ទៃទឹកមួយផ្នែកទៀតមាននៅតាមបឹងបួ ព្រែក និងប្រឡាយ។

**៤-តំបន់ការពារ រួមមាន៖**

- កសិទេសចរណ៍កោះអន្លង់ចិន មានផ្ទៃដីប្រមាណ៥១៥,៩៥ ហិកតា ស្មើនឹង២១,៧៦%

**៥-តំបន់ផ្សេងៗ៖**

ទីតាំងទុកដាក់សំរាម ឬប្រមូលសំរាមគ្រោងរៀបចំចំនួន៤ ទីតាំងដូចជា៖

- ប្រមូលសំរាម ក្នុងក្រុងតាខ្មៅត្រូវបានគ្រោងរៀបចំនៅដើម្បីយកទៅចាក់ ឬកែច្នៃសំរាម ស្ថិតនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង មានផ្ទៃក្រឡាប្រមាណ២,៦ ហិកតា
- ទីតាំងទី១. ស្ថិតនៅព្រែកសំរោង៣ សង្កាត់តាខ្មៅ មានចម្ងាយ៥៨០ ម៉ែត្រ ពីផ្លូវជាតិលេខ២១
- ទីតាំងទី២. ស្ថិតនៅភូមិព្រែកហូរកើត១ សង្កាត់ព្រែកហូរ មានចម្ងាយ៣ ១០០ ម៉ែត្រ ពីផ្លូវជាតិលេខ២១

- ទីតាំងទី៣. ស្ថិតនៅភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ មានចម្ងាយ៣៥០ ម៉ែត្រ ពីផ្លូវជាតិលេខ១១៥អា
- ទីតាំងទី៤. ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ មានចម្ងាយ៥៨០ ម៉ែត្រ ពីផ្លូវជាតិលេខ២១

អាងប្រព្រឹត្តិកម្មទឹកកខ្វក់គ្រោងរៀបចំនួន៥ ទីតាំងដូចជា៖

- ទីតាំងទី១. ស្ថិតនៅភូមិសិត្បូ ឃុំសិត្បូ មានចម្ងាយ១៨០០ ម៉ែត្រពីផ្លូវជាតិលេខ២១អា
- ទីតាំងទី២. ស្ថិតនៅភូមិព្រែកសំរោង១ សង្កាត់ព្រែកហូរ មានចម្ងាយ១៥០០ ម៉ែត្រពីផ្លូវជាតិលេខ២១
- ទីតាំងទី៣. ស្ថិតនៅភូមិព្រែកឡុង ឃុំរកាខ្ពស់ មានចម្ងាយ៣៣០០ ម៉ែត្រពីផ្លូវជាតិលេខ២១
- ទីតាំងទី៤. ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ មានចម្ងាយ៣៣០០ ម៉ែត្រពីផ្លូវជាតិលេខ២១
- ទីតាំងទី៥. ស្ថិតនៅភូមិព្រែកឡុង ឃុំរកាខ្ពស់ មានចម្ងាយ២៤០០ ម៉ែត្រពីផ្លូវជាតិលេខ២១

តំបន់ស្ថានីយបូមទឹកគ្រោងរៀបចំចំនួន២៦ ទីតាំង ដូចជា៖

- ទីតាំងទី១. មានចំនួន២ ទីតាំង ស្ថិតនៅក្នុងភូមិព្រែកតាពៅ និងភូមិដើមមៀន១ សង្កាត់ដើមមៀន
- ទីតាំងទី២. មានចំនួន៤ ទីតាំង ស្ថិតនៅក្នុងភូមិតាខ្មៅ ភូមិតាខ្មៅ១ ភូមិតាខ្មៅ៣ និងភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ
- ទីតាំងទី៣. មានចំនួន៣ ទីតាំង ស្ថិតនៅក្នុងភូមិក្រពើហា ភូមិព្រែកឫស្សី និងភូមិព្រែកឫស្សីលិច សង្កាត់ព្រែកឫស្សី
- ទីតាំងទី៤. មានចំនួន៣ ទីតាំង ស្ថិតនៅក្នុងភូមិព្រែករាំង និងភូមិព្រែកសំរោង១ សង្កាត់កំពង់សំណាញ់
- ទីតាំងទី៥. មានចំនួន១ ទីតាំង ស្ថិតនៅក្នុងភូមិព្រែកកាត់ សង្កាត់តាក្តុល
- ទីតាំងទី៦. មានចំនួន៣ ទីតាំង ស្ថិតនៅក្នុងភូមិបត្តាជី ព្រែកហូរកើត និងភូមិព្រែកហូរកើត១ សង្កាត់ព្រែកហូរ
- ទីតាំងទី៧. មានចំនួន២ ទីតាំង ស្ថិតនៅភូមិលេខ៣ និងភូមិលេខ៥ ឃុំស្វាយរលំ
- ទីតាំងទី៨. មានចំនួន៣ ទីតាំង ស្ថិតនៅភូមិសិត្បូមាន២ ទីតាំង និងភូមិកំពង់ព្រីង
- ទីតាំងទី៩. មានចំនួន១ ទីតាំង ស្ថិតនៅតាមច្រាំងទន្លេ ឃុំកោះអន្លង់ចិន
- ទីតាំងទី១០. មានចំនួន៣ ទីតាំង ស្ថិតនៅភូមិព្រែកថី ភូមិព្រែកសំរោង និងភូមិព្រែកខ្សេវ មាន២ ទីតាំង នៃឃុំរកាខ្ពស់។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់នេះ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម

រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការអភិវឌ្ឍដី។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបាន ដោយមិនចាំបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង១០% ឆ្លាតម្លាតអគារខាងមុខយ៉ាងតិច ១០ ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្ដាលគម្លាតអគារខាងមុខកម្ពស់អគារអតិបរមាស្មើនឹង៨ ម៉ែត្រ សួនច្បារដែលអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច៦៥%នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច១ ដើមសម្រាប់ផ្ទៃក្រឡាដីឡូត៍៤៩ ម៉ែត្រក្រឡា។

**ខ)-ប្រភេទដីអាចសាងសង់បាន**

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចក្ខុវិស័យឆ្នាំ២០៣០ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជាតំបន់។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍សួនច្បារដែលអាចជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ឆ្លាតម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកតំបន់នៃផែនការប្រើប្រាស់ដីដូចខាងក្រោម៖

**១-តំបន់លំនៅឋាន៖** មានផ្ទៃដីប្រមាណ៤ ០១៣,៣ ហិកតា ស្មើនឹង៤៥,៤០% ស្ថិតនៅសង្កាត់ដើមមៀន សង្កាត់តាខ្មៅ សង្កាត់ព្រែកឫស្សី សង្កាត់តាក្ដុល សង្កាត់កំពង់សំណាញ់ និងសង្កាត់ស្វាយរលំ ស្របតាមផ្លូវជាតិលេខ២១ និង២១អា រហូតដល់ព្រំប្រទល់ស្រុកស្អាង។ តំបន់លំនៅឋានត្រូវបានកំណត់បែងចែកជា៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
- តំបន់លំនៅឋានចម្រុះ ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០។

២-តំបន់ពាណិជ្ជកម្ម៖ មានផ្ទៃដីប្រមាណ៧០៣,៨៧ ហិកតា ស្មើនឹង៧,៩៦% ដែលមានចំនួន ២ ទីតាំងដូចជា៖

- ទីតាំងទី១. ស្ថិតនៅក្នុងសង្កាត់ស្វាយរលំ ជុំវិញចំណុចប្រសព្វរវាងផ្លូវក្រវាត់ក្រុងតាខ្មៅទី២ និងក្រវាត់រាជធានីភ្នំពេញទី៣
- ទីតាំងទី២. ស្ថិតនៅក្នុងសង្កាត់ព្រែកហូរ ត្រង់ចំណុចប្រសព្វនៃផ្លូវក្រវាត់ក្រុងតាខ្មៅទី១ ជាមួយនឹងផ្លូវសម្តេចតេជោពីរាជធានីភ្នំពេញ និងមួយចំនួនតូចស្ថិតនៅលាយក្នុងតំបន់ចម្រុះ

**តំបន់ពាណិជ្ជកម្មត្រូវបានកំណត់បែងចែកជា៖**

- តំបន់ពាណិជ្ជកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៦,០
- តំបន់ពាណិជ្ជកម្មចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

៣-តំបន់ឧស្សាហកម្ម៖ មានផ្ទៃដីប្រមាណ១២៩៩,៦៧ ហិកតា ស្មើនឹង១៤,៧០% មានចំនួន ៣ ទីតាំងដូចជា៖

- ទីតាំងទី១. ស្ថិតនៅក្នុងសង្កាត់ព្រែកហូរ នៅត្រង់ចំណុចប្រសព្វនៃផ្លូវក្រវាត់ក្រុងតាខ្មៅទី១ នឹងផ្លូវក្រវាត់ក្រុងភ្នំពេញទី៣ ដែលនៅជាប់នឹងតំបន់ពាណិជ្ជកម្មព្រែកហូរ
- ទីតាំងទី២. ស្ថិតនៅសង្កាត់សិត្បូ នៅត្រង់ចំណុចប្រសព្វនៃផ្លូវក្រវាត់ក្រុងតាខ្មៅទី១ នឹងផ្លូវលេខ២១អា រហូតដល់ផ្លូវជាតិលេខ២១ ត្រង់ចំណុចមុខវត្តឈ្វងលៀប
- ទីតាំងទី៣. ស្ថិតនៅសង្កាត់រកាខ្ពស់ជាប់នឹងផ្លូវក្រវាត់ក្រុងតាខ្មៅទី១។

**តំបន់ឧស្សាហកម្មត្រូវបានកំណត់បែងចែកដូចជា៖**

- តំបន់ឧស្សាហកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
- តំបន់ឧស្សាហកម្មស្រាល ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
- តំបន់ឧស្សាហកម្មចម្រុះ ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០។

៤-តំបន់ចម្រុះ៖ ត្រូវមានផ្ទៃដីប្រមាណ៧៩៦,០៩ ហិកតា ស្មើនឹង៩,០១% ដែលមានចំនួន៣ ទីតាំងដូចជា៖

- ទីតាំងទី១. ស្ថិតនៅក្នុងសង្កាត់តាខ្មៅ នៃទិសពាយ័ព្យជាប់នឹងព្រំប្រទល់រាជធានីភ្នំពេញ
- ទីតាំងទី២. ស្ថិតនៅក្នុងសង្កាត់សិត្បូ ចន្លោះបឹងឆ្មោតនឹងផ្លូវក្រវាត់ក្រុងតាខ្មៅទី១
- ទីតាំងទី៣. ស្ថិតនៅក្នុងសង្កាត់រកាខ្ពស់ ជាប់នឹងចំណុចប្រសព្វនៃផ្លូវជាតិលេខ២១ និងផ្លូវក្រវាត់រាជធានីភ្នំពេញទី៣។ តំបន់ចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

៥-តំបន់ដឹកជញ្ជូន៖ មានផ្ទៃដីប្រមាណ៤៧,៨៩ ហិកតា ស្មើនឹង០,៥៤% ស្ថិតនៅសង្កាត់តាខ្មៅ រួមមាន ផែកាណូតដឹកជញ្ជូន ចំណតរថយន្តតាក់ស៊ី ចំណតរថយន្តសាធារណៈ ស្ថានីយរថយន្តក្រុង និងនៅតាមតំបន់នៃគម្រោងស្នើសុំចាំបាច់មួយចំនួនទៀត។

**៦-តំបន់ទេសចរណ៍៖** មានផ្ទៃដីប្រមាណ៩៣៦,២៩ ហិកតា ស្មើនឹង១០,៥៩% មាន៦ ទីតាំង ស្ថិតនៅក្នុងសង្កាត់តាខ្មៅ ឃុំស្វាយរលំ ឃុំសិត្បូ និងឃុំរកាខ្ពស់ មានជាអាទិ៍សណ្ឋាគារ រមណីយដ្ឋាន ភោជនីយដ្ឋាន កាស៊ីណូ ផ្ទះសំណាក់ និងកន្លែងកម្សាន្ត។ តំបន់ទេសចរណ៍ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

**៧-តំបន់រដ្ឋបាលនិងសេវាសាធារណៈ៖** មានផ្ទៃដីប្រមាណ១៥២,៧៨ ហិកតា ស្មើនឹង១,៧៣% មានដូចជា សាលាខេត្ត សាលាក្រុង សាលាសង្កាត់ សាលាដំបូង មន្ទីរ អង្គភាព ទីបញ្ជាការដ្ឋាន អង្គរក្ស ស្នងការដ្ឋាន អធិការដ្ឋាន សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ កីឡដ្ឋាន សារមន្ទីរ ប៉ុស្តិ៍នគរបាល ប៉ុស្តិ៍ប្រៃសណីយ៍។ តំបន់រដ្ឋបាលខេត្តថ្មីស្ថិតនៅក្នុងសង្កាត់រកាខ្ពស់ ជាប់នឹងចំណុចប្រសព្វផ្លូវក្រវាត់ក្រុងតាខ្មៅទី២ និងផ្លូវជាតិលេខ២១។ តំបន់រដ្ឋបាលនិងសេវាសាធារណៈត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

**៨-តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង៖** មានផ្ទៃដីប្រមាណ៨៦៤,២៧ ហិកតា ស្មើនឹង៩,៧៨% ស្ថិតនៅតាមដីចំណើទន្លេបាសាក់ស្ថិតនៅក្នុងសង្កាត់តាខ្មៅ នៅតាមស្ទឹងព្រែកត្នោត និងមួយចំនួនទៀតស្ថិតនៅគ្រប់តំបន់ទាំងអស់នៃក្រុងតាខ្មៅ រួមមាន សួនច្បារតាមដងទន្លេបាសាក់ សួនច្បារនៅមុខសាលាខេត្ត សួនច្បារសាធារណៈតាមដងស្ទឹងព្រែកហូរ ចិញ្ចើមផ្លូវ និងបណ្ដាញបៃតងតាមចិញ្ចើមផ្លូវ ផ្ទៃបៃតងនៃក្រុងតាខ្មៅគ្រោងបន្ថែមឱ្យបាន១០ ម៉ែត្រក្រឡា សម្រាប់មនុស្សម្នាក់។ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,១។

**៩-តំបន់វប្បធម៌និងសាសនា៖** មានផ្ទៃដីប្រមាណ២៥,៣៨ហិកតា ស្មើនឹង០,២៩% នៃផ្ទៃដីសរុប ស្ថិតនៅក្នុងសង្កាត់តាខ្មៅ សង្កាត់តាក្ដុល សង្កាត់ព្រែកឫស្សី សង្កាត់ព្រែកហូរ ឃុំស្វាយរលំ ឃុំសិត្បូ និងមាននៅទីតាំងមួយចំនួនទៀត ស្ទើរនៅគ្រប់សង្កាត់ទាំងអស់ មានដូចជា វត្តអារាម វិហារចិន ព្រះវិហារអ៊ីស្លាម។ តំបន់វប្បធម៌និងសាសនាត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,០។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីអាចសាងសង់បាន តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ស្របតាមអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការអភិវឌ្ឍដី។

## ៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្រុងតាខ្មៅ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍទេសចរណ៍តំបន់ ក៏ដូចជានៅទូទាំងប្រទេសកម្ពុជា។ ក្រុងតាខ្មៅមានសក្ដានុពលទេសចរណ៍ជាច្រើន ដូចជា

តំបន់វប្បធម៌ប្រវត្តិសាស្ត្រផ្នែកកណ្តាលក្រុង តំបន់ទេសចរណ៍ធម្មជាតិតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ ព្រែក និងស្ទឹងបឹងបួជាច្រើន។

**៤.២.១-តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង**

- ជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងផលិតផលទេសចរណ៍រួមមានការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិព័រណ៍ផលិតផលក្នុងស្រុក
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សាររាត្រី លំនៅឋានទេសចរណ៍
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវសម្រាប់ដឹកជញ្ជូន និងផ្លូវថ្មើរជើង សម្រាប់មនុស្សទាំងអស់គ្នាដោយរៀបចំឱ្យមានផ្លូវសម្រាប់រថយន្ត កង់ ថ្មើរជើង និងបណ្តាញបៃតង ធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- សុវត្ថិភាពចំណីអាហារក៏ត្រូវតែយកចិត្តទុកដាក់ ដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដា និងបញ្ហាជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ
- ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសាធារណៈ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពលួច ឆក់ ការបាត់បង់របស់របរភ្ញៀវ នៅតាមដងផ្លូវ កន្លែងកម្សាន្ត កន្លែងស្នាក់នៅ និងកន្លែងផ្សេងៗទៀត
- ថែរក្សា និងការពារនូវសំណង់សម្រាប់បម្រើវិស័យវប្បធម៌ ដូចជារោងភាពយន្ត និងអគារវប្បធម៌ ព្រមទាំងជំរុញឱ្យមានការបើកដំណើរការឡើងវិញនូវទីតាំងទាំងនោះ។

**៤.២.២-តំបន់ទេសចរណ៍ធម្មជាតិ**

- ជំរុញការរៀបចំអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងទេសចរណ៍កែច្នៃនៅតាមព្រៃលិចទឹក និងនៅតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ និងបឹងបួនានា
- រៀបចំចងក្រងសហគមន៍ទេសចរណ៍ អភិវឌ្ឍន៍ទេសចរណ៍ស្នាក់នៅ និងលក់ផលិតផលក្នុងតំបន់រមណីយដ្ឋាន
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារធនធាន និងជីវចម្រុះតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងត្នោត បឹងរាន បឹងទឹកជោរ បឹងចាន់សារ និងបឹងទទឹងថ្ងៃ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតទូក ផ្លាកសញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព

- លើកទឹកចិត្តឱ្យមានការបើកដំណើរការឡើងវិញនូវនាវាកម្សាន្តនៅតាមបណ្តោយទន្លេបាសាក់ កោះអន្លង់ចិន និងស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងទទឹងថ្ងៃ បឹងត្នោត បឹងទឹកជោរ ដើម្បីបំពេញនូវតម្រូវការទេសចរណ៍ក្នុងស្រុក និងក្រៅស្រុក
- រៀបចំតាមបណ្តោយដងស្ទឹងព្រែកត្នោត និងទន្លេបាសាក់ ជាសួនច្បារ ជាតំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិ ដែលមានអនាម័យបរិស្ថានល្អ រក្សានូវលក្ខណៈដើមធម្មជាតិរបស់ទន្លេ និងស្ទឹង ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍
- ជំរុញឱ្យមានការរៀបចំកម្មវិធីប្រពៃណី និងកម្សាន្តផ្សេងៗដូចជាកម្មវិធីរាំរបាំបុរាណ ការប្រកួតអក្សរសាស្ត្រ សិល្បៈចម្រៀង ប្រណាំងទូក វត់ប្រណាំង ទិវាបរិស្ថានទីក្រុងស្អាត ដើម្បីលើកស្ទួយវិស័យទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ទាំងមូលហើយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈភូមិមួយផលិតផលមួយ និងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរនៅតាមផ្លូវកម្សាន្ត
- យកចិត្តទុកដាក់ និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេស ត្រូវបណ្តុះបណ្តាល មន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់។

### ៤.២.៣- ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

ទីតាំងក្រុងតាខ្មៅជាទីរួមខេត្តកណ្តាល ដែលមានសក្តានុពលផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ ការរស់នៅ និងបំពេញការងារ ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច សង្គមកិច្ចកើនឡើងឆាប់រហ័ស។ ក្រុងតាខ្មៅមានសក្តានុពលទេសចរណ៍វប្បធម៌ និងធម្មជាតិដែលត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញទេសចរ ទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍នៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ ជូនប្រជាជនមូលដ្ឋាន គឺជាអាទិភាព។ ដូចនេះ អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់៖

- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍
- កែលម្អ និងបង្កើតផលិតផលទេសចរណ៍
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍។

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស

- ជំរុញការបណ្តុះបណ្តាលជំនាញ ដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដាទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈក្រុងតាខ្មៅលើវិស័យទេសចរណ៍
- ចលនាផ្ទៃកងឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ផ្តល់អាទិភាព និងលើកស្ទួយការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធ ទៅតាមប្លង់គោលដែលបានកំណត់សម្រាប់បង្កភាពងាយស្រួល ដល់ការអភិវឌ្ឍជាយុទ្ធសាស្ត្រនៅក្នុងតំបន់រួមមាន៖

៤.៣.១-អ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ភ្ជាប់ទៅអន្តរជាតិ

ផ្លូវជាតិលេខ២១ ជាផ្លូវជាតិសំខាន់ជាងគេ ដែលមានតួនាទីជាអ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម ចាំបាច់ត្រូវពង្រីកទទឹងផ្លូវដែលមានស្រាប់ និងធ្វើការសាងសង់ផ្លូវវាងក្រុងបន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូន និងចរាចរណ៍។

៤.៣.២-ផ្លូវថ្នល់

- រៀបចំ និងកែលម្អផ្លូវពាណិជ្ជកម្ម ដោយកំណត់ផ្លូវជាតិលេខ២១ ជាផ្លូវសម្រាប់ចរាចរណ៍ធុនស្រាល
- រៀបចំឱ្យមានភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺតាមដងផ្លូវ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ និងលេខផ្លូវឱ្យបានគ្រប់ផ្លូវទាំងអស់
- បង្កើតបណ្តាញផ្លូវថ្នល់ភ្ជាប់ទំនាក់ទំនងរវាងទីប្រជុំជនក្រុង ទៅតំបន់ជាយក្រុង ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ ដឹកជញ្ជូន និងកាត់បន្ថយថ្លៃចំណាយក្នុងការធ្វើដំណើរ
- រៀបចំចិញ្ចើមផ្លូវសម្រាប់ទុកកន្លែងឱ្យអ្នកថ្មើរជើងធ្វើដំណើរមានភាពងាយស្រួល និងធានាបាននូវសុវត្ថិភាព
- រៀបចំឱ្យមានស្ពានអាកាសសម្រាប់ថ្មើរជើងឆ្លងកាត់ផ្លូវនៅតាមកន្លែងមួយចំនួន ដែលមានមនុស្សឆ្លងកាត់ច្រើន ដូចជាសាលារៀន ផ្សារ មន្ទីរពេទ្យ កន្លែងកម្សាន្ត និងកោះចក្រជាដើម ដើម្បីងាយស្រួល និងបញ្ចៀសគ្រោះថ្នាក់ចរាចរណ៍
- បង្កើតផ្លូវថ្មី និងតភ្ជាប់កំណាត់ផ្លូវដែលទាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចរាចរណ៍បច្ចុប្បន្ន និងអនាគត

- ជំរុញកសាងផ្លូវវាងក្រុងតាមផែនការប្លង់គោលប្រើប្រាស់ដី ដើម្បីបញ្ចៀសរថយន្តដឹកទំនិញធុនធ្ងន់ចូលក្នុងទីក្រុង និងការកាត់បន្ថយបញ្ហាកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ ការហុយធូលី និងការបាត់នូវសណ្តាប់ធ្នាប់ សោភ័ណភាពក្រុង
- លើកទឹកចិត្តអ្នកចូលរួមគាំទ្រ ក្នុងការពង្រីកផ្លូវនៅតាមមូលដ្ឋាន ដើម្បីសម្រួលចរាចរណ៍ធ្វើដំណើរទៅវិញទៅមក
- កំណត់ទីតាំងសម្រាប់រៀបចំជាចំណតរថយន្តក្រុង និងចំណតទូទៅ នៅក្នុងទីប្រជុំជនក្រុង និងតាមសង្កាត់នានា
- ពង្រីក និងកែលម្អនូវបណ្តាញផ្លូវថ្នល់ទាំងអស់ឱ្យមានលក្ខណៈធំទូលាយសមរម្យ និងមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡាគ្នា ដើម្បីកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍
- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

**៤.៣.៣-ផ្លូវទឹក**

- រៀបចំមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទ ដើម្បីសម្រួលដល់ការធ្វើដំណើរទូទៅ និងប្រកបការងារ
- សាងសង់ឱ្យមានកំពង់ផែ សម្រាប់ការលើកដាក់ និងដឹកជញ្ជូនទំនិញចេញចូល នៅតាមដងទន្លេបាសាក់
- រៀបចំ និងបង្កើនមធ្យោបាយទេសចរណ៍ផ្លូវទឹកឱ្យបានច្រើន ដើម្បីអូសទាញភ្ញៀវទេសចរ និងកំណើនសេដ្ឋកិច្ច
- ជួសជុល កែលម្អស្ពានចាស់ទ្រុឌទ្រោម និងកសាងស្ពានថ្មីឆ្លងកាត់ទន្លេ ស្ទឹង ព្រែកឱ្យបានច្រើនសមស្រប ដើម្បីសម្រួលដល់ការធ្វើដំណើរ ការដឹកជញ្ជូនទាំងផ្លូវទឹក និងផ្លូវគោក
- កែលម្អ ស្តារឡើងវិញ និងកសាងបណ្តាញផ្លូវទឹក នៅតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ ព្រមទាំងព្រែក អូរ ប្រឡាយ និងបឹងបួរបស់ក្រុង សម្រាប់បម្រើវិស័យទេសចរណ៍
- ការផ្គត់ផ្គង់ទឹក និងការរំដោះទឹក
- រៀបចំប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការ។

**៤.៣.៤-ផ្លូវអាកាស**

- រៀបចំបង្កើតអាកាសយានដ្ឋានអន្តរជាតិក្រុងតាខ្មៅ ជាមួយនឹងស្រុកកណ្តាលស្ទឹង ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំណើនសេដ្ឋកិច្ច និងភ្ញៀវទេសចរណ៍ដែលកាន់តែមានកំណើនខ្ពស់
- រៀបចំផែនការប្រើប្រាស់ដីលម្អិតក្នុងតំបន់ និងនៅជុំវិញផ្លូវអាកាស ដើម្បីរក្សាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍប្រកបដោយចីរភាព។

### ៤.៣.៥-ថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ជំរុញ ស្តារ និងអភិវឌ្ឍវិស័យថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម និងលំនៅឋាន
- ពង្រីក និងកែលម្អប្រព័ន្ធអគ្គិសនីដែលមានស្រាប់ ដើម្បីរក្សាតុល្យភាពទៅនឹងកំណើនប្រជាជន និងតម្រូវការផ្គត់ផ្គង់អគ្គិសនី ក្នុងក្រុងតាខ្មៅ ដែលកំពុងតែមានកំណើនខ្ពស់
- រៀបចំ ជួសជុល កែលម្អ និងសាងសង់បង្គោលភ្លើងថ្មី និងប្រព័ន្ធខ្សែភ្លើងសម្រាប់ការគ្រប់គ្រង និងចែកចាយអគ្គិសនី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ចៀសវាងការបង្កគ្រោះថ្នាក់ និងការបាត់បង់នូវសោភ័ណភាពក្រុង
- ពង្រីកប្រព័ន្ធបណ្តាញអគ្គិសនីបន្ថែមទៅដល់សង្កាត់ថ្មីទាំង៤ នៃក្រុងតាខ្មៅ
- រៀបចំផ្លូវរង្វង់មូល និងដាក់ភ្លើងស្តុបបន្ថែមនៅតាមផ្លូវដែលមានចរាចរណ៍ច្រើន ដើម្បីកាត់បន្ថយភាពកកស្ទះ និងសុវត្ថិភាពតាមដងផ្លូវ។

### ៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- ជំរុញ ស្តារ និងរៀបចំលម្អសាធារណៈនិងផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបានសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈ និងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់កម្រិត តាមភូមិ សង្កាត់ ក្នុងក្រុងតាខ្មៅ ស្របតាមអនុក្រឹត្យស្តីពីនគូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន នៅតាមសង្កាត់ និងក្នុងក្រុងស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- ថែរក្សាទីតាំងវប្បធម៌ សាសនា និងសម្បត្តិបេតិកភណ្ឌ ដូចជាវិហារចិន វិហារឥស្លាម និងវត្តខ្មែរបុរាណ។

### ៤.៣.៧-ការផ្គត់ផ្គង់ទឹកស្អាត

#### ក)-ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្រុង

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងក្រុងតាខ្មៅ។ ប្រព័ន្ធដែលមានស្រាប់ ត្រូវកែលម្អបន្ថែម និងពង្រីកដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ តម្រូវការបន្ទាន់បំផុតសម្រាប់ការកែលម្អនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ទីក្រុង គឺមានតាមលំដាប់អាទិភាពដូចខាងក្រោម៖

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែលអាចមាន
- សិក្សាប្រភពទឹកដើម្បីធានានូវសក្តានុពលនៃទឹកក្រោមដីសម្រាប់ផ្គត់ផ្គង់ទឹកស្អាតតំបន់ក្រុង
- រៀបចំបទប្បញ្ញត្តិ និងការចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកសម្រាប់បម្រើដល់ការអភិវឌ្ឍតំបន់ក្នុងទីក្រុង
- ស្តារឡើងវិញ និងការដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើនគុណភាពទឹកតាមតម្រូវការជាក់ស្តែង
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងបង្កើនប្រាក់ចំណូលបន្ថែម
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស។

**ខ)-ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជាយក្រុង**

ប្រភពទឹកនៅតំបន់ជាយក្រុងតាខ្មៅ ស្ថិតនៅក្នុងឃុំស្វាយរលំ ឃុំរកាខ្ពស់ ឃុំសិត្បូ និងឃុំកោះអន្លង់ចិន

- រក្សា និងកំពុងត្រូវបានការពារជាប្រភពទឹកធម្មជាតិ សម្រាប់ប្រើប្រាស់ និងទេសចរណ៍កម្សាន្ត
- ស្តារ និងកែលម្អអាងស្តុកទឹក និងបណ្តាញចែកចាយទឹកដែលមានស្រាប់ ដើម្បីអភិវឌ្ឍ និងផ្គត់ផ្គង់ទឹកស្អាត
- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។

**៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក**

ដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋានទទួលបានផលប្រយោជន៍ល្អ ពីផលិតកម្ម កសិកម្ម គឺចាំបាច់ត្រូវៈ

- រក្សាទុកតំបន់កសិកម្មឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ កាត់បន្ថយ ឬទប់ស្កាត់ការបំលែងដីកសិកម្ម ទៅជាដីសាងសង់ និងផ្អែកតាមប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ។ ករណីចាំបាច់សម្រាប់ការពង្រីកតំបន់សាងសង់ ត្រូវអនុវត្តតាមលិខិតក្របខណ្ឌគតិយុត្តជាធរមាន
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ សំដៅលើកកម្ពស់ផលិតកម្មកសិកម្មតាមសហគមន៍ ដើម្បីបង្កើនការងារ និងប្រាក់ចំណូលរបស់ប្រជាជន
- បង្កើតផ្សារ សិក្សាទីផ្សារ និងផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ និងមណ្ឌលព័ត៌មានដើម្បីបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍អំពីស្តង់ដាបច្ចេកទេសកសិកម្មដល់ប្រជាជន

- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវការធ្វើកសិកម្មដែលបំផ្លាញធនធានធម្មជាតិ ប្រើប្រាស់ជី និងថ្នាំគីមី មិនគោរពតាមស្តង់ដាបច្ចេកទេស
- អភិវឌ្ឍធនធានមនុស្សដោយជំរុញការបណ្តុះបណ្តាលជំនាញដល់កសិករ ដោយអនុវត្តតាមស្តង់ដាកសិកម្ម និងចលនាផ្នែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន
- ជំរុញឱ្យមានការបង្កើតទីតាំងកែច្នៃផលិតផលកសិកម្ម ឱ្យបានច្រើនប្រភេទដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការប្រើប្រាស់
- ថែរក្សាទីតាំងតំបន់សម្រាប់ការលក់ដូរ និងផ្សាំបណ្តុះរុក្ខជាតិ កូនឈើ ផ្កា ឱ្យទៅជាតំបន់បៃតងនៅក្នុងសង្កាត់តាក្តុល សង្កាត់ព្រែកហូរ និងសង្កាត់ព្រែកឫស្សី ដើម្បីប្រែក្លាយជាតំបន់ទេសចរណ៍ធម្មជាតិតាមដងផ្លូវបៃតង តាមដងទន្លេបាសាក់ និងតាមដងស្ទឹងព្រែកត្នោត សម្រាប់ការលម្ហែកម្សាន្តរបស់ភ្ញៀវជាតិ និងអន្តរជាតិ។

## ៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីសាធារណៈ និងឯកជនរបស់រដ្ឋ ជាពិសេសនៅតាមមាត់ទន្លេបាសាក់ មាត់ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ នៅតាមដងផ្លូវសាធារណៈ និងមាត់បឹង
- សិក្សាផ្តល់លទ្ធភាព និងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុង និងប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្នគ្រប់កន្លែង ជាពិសេសក្នុងតំបន់សំណង់បុរាណក្នុងក្រុង
- ពង្រឹងសេវាកម្មដោះស្រាយហានិភ័យ សង្គ្រោះបន្ទាន់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយនានា ដូចជាគ្រោះអគ្គិភ័យ ទឹកជំនន់ និងបាតុភូតធម្មជាតិផ្សេងៗ
- ពង្រឹងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈ ឱ្យមានអភិបាលកិច្ចល្អគ្រប់ស្ថាប័នទាំងអស់ និងលើកទឹកចិត្តការប្រតិបត្តិតាមច្រកចេញចូលតែមួយ។

## ៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ

### ៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

- បង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងការគ្រប់គ្រងសំណល់រឹងខេត្ត និងក្រុងតាខ្មៅ
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងកំណត់ទីតាំងទុកដាក់សំរាមនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹងមានផ្ទៃដីប្រមាណ២,៦ ហិកតា សម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើប ក្នុងការកែច្នៃគ្រប់គ្រងសំណល់រឹង
- ជំរុញឱ្យមានការអនុវត្តច្បាប់ឱ្យបានតឹងរឹងស្របតាមគោលការណ៍ កាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិក ផលិតផលប៉ះពាល់បរិស្ថាន និងរៀបចំឱ្យមានរោងចក្រកែច្នៃសំណល់រឹងឱ្យមានប្រសិទ្ធភាព ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងការវិនិយោគរបស់រដ្ឋ និងវិស័យឯកជន។

### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- រៀបចំ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវធ្វើចម្រោះទឹកកខ្វក់ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចេញទៅលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈ ឱ្យអនុវត្តច្បាប់ និងបទដ្ឋានបច្ចេកទេសបានល្អ ក្នុងការរៀបចំឱ្យមានអាងចម្រោះទឹកកខ្វក់ ប្រព័ន្ធបង្គា និងអាងអនាម័យត្រឹមត្រូវ
- កែលម្អ និងពង្រីកបន្ថែមអាងស្តុកទឹកភ្លៀង និងទឹកកខ្វក់ ស្ថានីយបូមទឹក និងសាងសង់ស្ថានីយ៍ចម្រោះទឹកកខ្វក់
- រក្សាឱ្យមានតុល្យភាពរវាងតំបន់ក្រាលថ្មបេតុង និងតំបន់បៃតង ដោយលើកទឹកចិត្តប្រជាពលរដ្ឋឱ្យដាំដើមឈើ ដាំផ្កា រុក្ខជាតិផ្សេងៗ និងរៀបចំជាសួនច្បារជ្រាបទឹកនៅតាមដីឡូតិ៍ឯកជនឱ្យបានច្រើន
- សម្អាតបរិស្ថានតាមទីសាធារណៈ ជាពិសេសនៅតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត និងស្ពានផ្លូវទឹកធម្មជាតិផ្សេងៗ ព្រមទាំងទប់ស្កាត់ការបោះចោលសំរាមលើផ្ទៃទឹក និងតាមទីសាធារណៈ
- ទប់ស្កាត់ការលុបបឹង និងប្រព័ន្ធផ្លូវទឹកធម្មជាតិក្នុងការយកដីទៅសាងសង់សំណង់ផ្សេងៗ
- បង្កើតនូវបទប្បញ្ញត្តិជាក់លាក់ក្នុងការគ្រប់គ្រងកាកសំណល់រឹង រាវ និងទប់ស្កាត់ការបំពុលបរិស្ថាន បណ្តាលមកពីរោងចក្រ សហគ្រាស សិប្បកម្ម និងអាជីវកម្ម
- រៀបចំបង្កើតទិវាបរិស្ថានទីក្រុងស្អាត និងអប់រំផ្សព្វផ្សាយប្រជាជនឱ្យយល់ពីបញ្ហាបរិស្ថាន និងការការពារចំពោះការប្រែប្រួលអាកាសធាតុ។

### ៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

- តំបន់វប្បធម៌តាមវត្តអារាម វិហារចិន សាលារៀន មន្ទីរពេទ្យ
- តំបន់ផ្សារតាខ្មៅចាស់ និងថ្មី
- តំបន់តាមមាត់ទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងទទឹងថ្ងៃ បឹងរាន បឹងទឹកជោរ
- តំបន់តាមដងផ្លូវជាតិលេខ២ និងផ្លូវលេខ២១
- តាមដងទន្លេបាសាក់ បឹងត្នោត បឹងរាន និងបឹងទឹកជោរ។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារ និងថែរក្សាជីវចម្រុះក្នុងទន្លេដែលជាកន្លែងមានតួនាទីសំខាន់សម្រាប់ត្រីពង-កូន និងរកចំណីធនធានវារិជាត នៃគ្រប់ប្រភេទត្រី

- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន និងបង្កើនការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើនបំផុតលើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាន និងប៉ះពាល់សណ្តាប់ធ្នាប់
- កាត់បន្ថយការបូមទឹកក្រោមដីរបស់ឯកជន តាមរយៈការពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីក្នុងក្រុង ប្រកបដោយប្រសិទ្ធភាព
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការសាងសង់នៃគម្រោងអភិវឌ្ឍន៍និងវិនិយោគនានា។

**៤.៧- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម**

- ធ្វើការបែងចែកជាតំបន់សម្រាប់ការវិនិយោគពាណិជ្ជកម្មបច្ចុប្បន្ននិងទៅអនាគតឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ
- កែលម្អ និងពង្រីកទីផ្សារលក់ដូរ ដើម្បីឱ្យប្រជាពលរដ្ឋ និងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយសមស្រប និងមានសណ្តាប់ធ្នាប់
- កែលម្អទីផ្សារមានស្រាប់ទាំងឯកជន និងសាធារណៈ ឱ្យមានលក្ខណៈស្តង់ដាររួមមានចំណតយានយន្ត ច្រកដើរក្នុងផ្សារ បណ្តាញទឹក ភ្លើង តំបន់បៃតង ហេដ្ឋារចនាសម្ព័ន្ធកម្សាន្ត ឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ។ រៀបចំថ្មី ឬកែលម្អផ្សារលក់ដូរដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- លើកទឹកចិត្តឱ្យមានការវិនិយោគ ដោយបង្កើតជាផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ ឃ្លាំង សហគ្រាសផ្សេងៗ ដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច
- រៀបចំបង្កើតឃ្លាំងស្តុកទំនិញក្នុងក្រុង សម្រាប់ចែកចាយទៅរាជធានីភ្នំពេញ និងតំបន់ជុំវិញ ព្រមទាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អ ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន
- បង្កើនការរៀបចំកម្មវិធីតាំងពិព័រណ៍ពាណិជ្ជកម្ម និងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទ ដើម្បីបង្កើនការផលិត និងជំរុញសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងក្រុងឱ្យបានខ្លាំងក្លា។

**៤.៨- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**

- រៀបចំបែងចែកជាតំបន់ឧស្សាហកម្មធុនស្រាល និងសិប្បកម្មឱ្យបានសមស្រប និងមានទីតាំងនៅដាច់ចេញតំបន់លំនៅឋាន
- លើកទឹកចិត្តដល់អ្នកវិនិយោគជាតិ និងអន្តរជាតិដែលមកធ្វើឧស្សាហកម្មបៃតងក្នុងទីក្រុង
- បង្កើនសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំក្រៅប្រទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់

- ជំរុញការអភិវឌ្ឍឧស្សាហកម្មធុនស្រាល ដែលប្រើគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើប សម្រាប់កែច្នៃផលិតផលកសិកម្ម និងសម្ភារៈប្រើប្រាស់ផ្សេងៗដើម្បីបំពេញនូវតម្រូវការប្រជាពលរដ្ឋក្នុងក្រុង និងសម្រាប់ចែកចាយទាំងក្នុង និងក្រៅប្រទេស
- លើកទឹកចិត្តដល់ការវិនិយោគលើវិស័យរោងចក្រកាត់ដេរ សហគ្រាស រោងចក្រដំឡើងយានយន្ត និងគ្រឿងអេឡិចត្រូនិក សិប្បកម្មដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋ ដើម្បីលើកស្ទួយជីវភាពរស់នៅ
- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មបច្ចុប្បន្ន ដែលប៉ះពាល់ដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ ដោយសាងសង់ ឬកែសម្រួលឡើងវិញស្របតាមស្តង់ដាបច្ចេកទេស និងប្លង់គោលប្រើប្រាស់ដីក្រុង
- លើកកម្ពស់ការប្រកួតប្រជែងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈវិស័យឧស្សាហកម្ម និងលើកទឹកចិត្តដល់អង្គភាពដែលមានស្នាដៃល្អ។

**៤.៩- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ**

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស ទេសភាពវប្បធម៌ និងធម្មជាតិជុំវិញ ដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ទឹកក្រោមដី និងការប្រើប្រាស់ដី
- រៀបចំ ស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដោយអង្គភាពរដ្ឋាករស្វយ័តក្រុងតាខ្មៅដល់ប្រជាជនក្នុងក្រុងឱ្យបាន១០០% ដើម្បីបញ្ឈប់ការបូមទឹកក្រោមដីរបស់វិស័យឯកជន ដែលអាចនាំឱ្យបរិមាណទឹកក្រោមដីថយចុះដែលអាចបង្កឱ្យមានការបាក់ច្រាំងទន្លេ ស្ទឹង
- សិក្សាប្រភពទឹកទន្លេ និងស្ទឹង ដើម្បីធានានូវតុល្យភាពនៃកម្ពស់ទឹកក្នុងវិស័យទេសចរណ៍
- សិក្សា និងរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីធ្វើសមាហរណកម្មព្រលានយន្តហោះនៃក្រុងតាខ្មៅ និងស្រុកកណ្តាលស្ទឹងឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព
- អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

**៤.១០- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន**

ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍក្រុង និងបរិស្ថានដូចជាៈ

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងខេត្ត
- ពង្រឹងមូលដ្ឋានធនធានមនុស្សនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ជាពិសេស សម្រាប់ការគ្រប់គ្រងការអភិវឌ្ឍ ការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។

- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេស សម្រាប់ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានទីក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគម្រោងប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗ ចាំបាច់ ដូចតទៅ៖

### ៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

តាមរយៈគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងតាខ្មៅ បទប្បញ្ញត្តិនគរូបនីយកម្ម ដែលត្រូវរៀបចំ រួមមាន៖

- បទប្បញ្ញត្តិនៃផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ទាំង១០ របស់ក្រុង
- ប្លង់លម្អិតនគរូបនីយកម្ម និងបទដ្ឋានបច្ចេកទេស សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍
- ផែនទីកំណត់កម្ពស់អគារ និងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់
- ផែនទីកំណត់ទីតាំងលម្អសាធារណៈ ផ្ទៃបៃតង ផ្លូវថ្នល់ កំពង់ផែ ស្ទឹង បឹងបួ ទំនប់ទឹក ប្រឡាយទឹក ប៉ុស្តិ៍ ស្ថានីយ អាកាសយានដ្ឋាន។ល។
- គ្រប់គ្រងតំបន់កម្រិតការសាងសង់ និងតំបន់អាចសាងសង់បាន ប្រកដោយប្រសិទ្ធភាព
- ណែនាំការនុវត្តបទប្បញ្ញត្តិតាមតំបន់ប្រើប្រាស់ដី និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ។

### ៥.២- ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅនេះដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ និងតាមរយៈគេហទំព័រ ឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្តកណ្តាល។

### ៥.៣- ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុង ទេសចរណ៍ កសិកម្ម និងការផ្សព្វផ្សាយផលិតផល ពាណិជ្ជកម្ម ការដឹកជញ្ជូន ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូ បង្ហូរ ទឹកភ្លៀងនិងសំណល់រាវ ការផ្គត់ផ្គង់ថាមពលអគ្គិសនី មានដូចខាងក្រោម៖

#### ៥.៣.១- ការអភិវឌ្ឍក្រុង

- កំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់

- ដាក់លេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល
- កែលម្អសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- កសាងសមត្ថភាពធ្វើផែនការក្រុង
- ធ្វើផែនការ និងអភិវឌ្ឍតំបន់វប្បធម៌ ទេសចរណ៍ និងតំបន់សណ្ឋាគារ
- អភិវឌ្ឍតំបន់លំនៅឋាន។

**៥.៣.២- ការអភិវឌ្ឍវិស័យទេសចរណ៍**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរៀបគម្រោងមួយចាំបាច់ ដើម្បីសម្រួលដល់ការធ្វើដំណើរក៏ដូចជាការទាក់ទាញភ្ញៀវទេសចរ
- លើកកម្ពស់គុណភាពនៃការគ្រប់គ្រងទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- លើកកម្ពស់សហគមន៍ទេសចរណ៍
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន
- ផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងតំបន់ទេសចរណ៍ ដូចជាបំភ្លឺតុបតែងដល់សេវាបម្រើទេសចរណ៍
- អភិវឌ្ឍកសិទេសចរណ៍ដ៏ប្រណីត មានទីតាំងស្ថិតនៅឃុំកោះអន្លង់ចិនមានចម្ងាយប្រមាណ៩ គីឡូម៉ែត្រពីក្រុងតាខ្មៅ និង១៩ គីឡូម៉ែត្រ ពីទីរួមស្រុកស្អាង ដែលហ៊ុមព័ទ្ធ ដោយទន្លេបាសាក់។ ឃុំកោះអន្លង់ចិនមានបណ្តោយ១២ គីឡូម៉ែត្រ ទទឹងតូចបំផុត៣០០ ម៉ែត្រ និងមានភូមិចំនួន០៤។

**៥.៣.៣- ការដឹកជញ្ជូន**

- ពង្រីកបណ្តាញទំហំផ្លូវ ចាប់ពី៨-១៥ ម៉ែត្រ២០-២៥ ម៉ែត្រ និង៣០ ម៉ែត្រ ៥០ ម៉ែត្រ និង ៦០ម៉ែត្រ
- កែសម្រួលបណ្តាញផ្លូវក្រវាត់ក្រុងតាខ្មៅទី១ ទី២ និងទី៣ រហូតឆ្នាំ២០៣០
- កែសម្រួលបណ្តាញផ្លូវក្រវាត់រាជធានីភ្នំពេញទី១ ទី២ និងទី៣ រហូតឆ្នាំ២០៣០
- ស្តារ និងជួសជុលបណ្តាញផ្លូវសំខាន់ៗក្នុងក្រុងតាខ្មៅ
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

**៥.៣.៤- ការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម**

- កសាងផ្លូវសម្រាប់សម្រួលដល់ការដឹកនាំទំនិញចេញចូល

- ផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងតំបន់ពាណិជ្ជកម្ម ដូចជាការបំភ្លឺ និងផ្តល់ថាមពលដល់ការលើកដាក់ទំនិញ
- កសាងផ្សារសម្រាប់លក់ដោះដូរទំនិញ និងឃ្លាំងសម្រាប់ស្តុក និងរក្សាទុកទំនិញ។

**៥.៣.៥-ការគ្រប់គ្រងបរិស្ថាន**

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងបរិស្ថាន
- ប្រែក្លាយក្រុងតាខ្មៅ ជាទីក្រុងមួយដែលមានលក្ខណៈល្អប្រសើរសម្រាប់ការរស់នៅ
- បង្កើនកន្លែងលម្ហែកម្សាន្ត និងតំបន់បៃតងនៅក្នុងក្រុង និងបន្តថែរក្សាតំបន់បៃតងដែលមានស្រាប់ស្ថិតនៅតាមសងខាងទន្លេបាសាក់ និងស្ទឹងព្រែកត្នោត។

**៥.៣.៦-ការគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកស្អាត**

- ត្រួតពិនិត្យអ្នកប្រើប្រាស់បណ្តាញផ្គត់ផ្គង់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ ដែលមានគុណភាពខ្ពស់
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី
- អភិវឌ្ឍរោងចក្រប្រព្រឹត្តកម្មទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងតាខ្មៅ។

**៥.៣.៧-ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងសំណល់រាវ**

- លើកកម្ពស់ប្រព័ន្ធបង្ហូរទឹកក្នុងក្រុង
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់កណ្តាលក្រុង
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកក្នុងក្រុងថ្មី
- គ្រប់គ្រងសំណល់រាវក្នុងក្រុង និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ជាពិសេសតំបន់លំនៅឋានថ្មីដែលត្រូវពង្រីកនៅប៉ែកខាងត្បូងក្រុង
- សាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងក្រុងតាខ្មៅ ដើម្បីធានាដល់បរិស្ថាននៃការរស់នៅ ការធ្វើអាជីវកម្ម និងបំពេញការងារ។

**៥.៣.៨-ការគ្រប់គ្រងសំណល់រឹង**

- បង្កើនសេវាកម្មគ្រប់គ្រងសំណល់រឹងតំបន់ដែលទទួលបានសេវាកម្មប្រមូលសំរាមត្រូវធ្វើការពង្រីកឱ្យបានគ្រប់ទីកន្លែងទាំងអស់នៅទូទាំងក្រុង ជាពិសេសនៅតំបន់លំនៅឋានដែលស្ថិតនៅតំបន់អភិវឌ្ឍន៍ថ្មីប៉ែកខាងត្បូងក្រុង
- ពង្រីកទីតាំងទុកដាក់សំរាមមានស្រាប់ឱ្យបានធំជាងមុននិងរៀបចំគ្រប់គ្រងទៅតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ។

### ៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍

- បំពាក់ម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូត
- ពង្រីកស្ថានីយថាមពលប្រើប្រេងម៉ាស៊ូត
- ពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនី និងទូរគមនាគមន៍
- ដំឡើង និងផ្លាស់ប្តូរបណ្តាញអគ្គិសនីបំភ្លឺតាមដងវិថី
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ដែលពុំទាន់មានការប្រើប្រាស់
- កសាងសមត្ថភាពអគ្គិសនីកម្ពុជា
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ញា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន

## ៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពនៃប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចែកចេញជា៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម៖

### ៥.៤.១-ការអនុវត្តរយៈពេលខ្លី

- ផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅនេះ ដល់អន្តរវិស័យ វិនិយោគិន និងប្រជាពលរដ្ឋ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលធនធានមនុស្ស និងមន្ត្រីជំនាញ
- កំណត់ទីតាំងគម្រោងអាទិភាព កសាងហេដ្ឋារចនាសម្ព័ន្ធ និងកែលម្អសោភ័ណភាពក្រុង
- កែលម្អ និងរៀបចំផ្សារមានស្រាប់ក្នុងក្រុងតាខ្មៅ
- កែលម្អ និងពង្រីកផ្លូវជាតិលេខ២១ ឆ្ពោះទៅកាន់ប្រទេសវៀតណាម
- ស្តារ និងកែលម្អប្រឡាយទឹកកខ្វក់ចំនួន៥ ខ្សែដូចជា៖
  - ខ្សែទី១ ស្ថិតនៅសង្កាត់កំពង់សំណាញ់ មានប្រវែង២៧៧១ ម៉ែត្រ
  - ខ្សែទី២ ស្ថិតនៅសង្កាត់កំពង់សំណាញ់ មានប្រវែង១៥៦០ ម៉ែត្រ
  - ខ្សែទី៣ ស្ថិតនៅសង្កាត់កំពង់សំណាញ់ និងព្រែកឫស្សី មានប្រវែង១៨៣៨ ម៉ែត្រ
  - ខ្សែទី៤ ស្ថិតនៅសង្កាត់កំពង់សំណាញ់ មានប្រវែង៤៥៤ ម៉ែត្រ
  - ខ្សែទី៥ ស្ថិតនៅសង្កាត់កំពង់សំណាញ់ មានប្រវែងប្រមាណ២២៤០ ម៉ែត្រ។
- រៀបចំ និងកែលម្អចំណតទូកស្ថិតនៅសង្កាត់តាខ្មៅ សម្រាប់ដឹកអ្នកដំណើរតាមទន្លេបាសាក់ ទៅកាន់ស្ថានីយច្បារអំពៅ ស្ថានីយចតុមុខ ស្ថានីយផ្សារចាស់ និងស្ថានីយឫស្សីកែវ
- សិក្សាកសាងផែនការប្រើប្រាស់ដីតាមសង្កាត់នីមួយៗ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍លម្អិត
- ចុះបញ្ជីដីធ្លីស្របតាមប្លង់គោល និងកែសម្រួលក្បាលដីចំពោះតំបន់ដែលបានចុះបញ្ជីហើយ

- សាងសង់ផ្លូវរណប ផ្លូវក្រវាត់ក្រុង និងផ្លូវនានា ដោយយោងតាមគម្រោងប្លង់គោល
- ដាក់លេខផ្ទះ និងលេខនិងឈ្មោះផ្លូវបន្ថែមនៅសង្កាត់ទាំង១០ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិទាំង១០ សង្កាត់
- រៀបចំកែលម្អកន្លែងប្រមូលសំរាម នៅតាមភូមិ និងសង្កាត់ទាំងអស់នៃក្រុងតាខ្មៅ
- កែលម្អ និងរៀបចំបន្ថែមទីតាំងស្ថានីយបូមទឹក
- រៀបចំលំនៅឋានតម្លៃសមរម្យស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ និងទីតាំងមួយចំនួនទៀត
- ជំរុញឱ្យមានការកសាងសាកលវិទ្យាល័យប្រចាំខេត្ត នៅសង្កាត់ព្រែកហូរ
- កសាងពហុកីឡដ្ឋានខេត្ត ដែលមានទំហំសមស្រប
- កំណត់បទប្បញ្ញត្តិប្រើប្រាស់ដី សំណង់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុង។

**៥.៤.២-ការអនុវត្តរយៈពេលមធ្យម**

- កសាងសមត្ថភាពគ្រប់គ្រងផែនការអភិវឌ្ឍក្រុង
- ផែនទីកំណត់តំបន់អភិវឌ្ឍន៍ជាអាទិភាព
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលធនធានមនុស្ស និងមន្ត្រីជំនាញ
- អនុវត្តដំណើរការសហគមន៍មួយ ផលិតផលមួយ
- រៀបចំទីតាំងស្ថានីយបូមទឹកចំនួន២៦ កន្លែង នៅសង្កាត់ទាំង៩ នៃក្រុងតាខ្មៅលើកលែងតែសង្កាត់ព្រែកហូរ
- រៀបចំទីតាំងប្រៃសនីយ៍ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់
- រៀបចំទីតាំងចាក់ និងកែច្នៃចំនួន១ ទីតាំង
- រៀបចំទីតាំងចាក់ និងប្រមូលសំរាមបណ្តោះអាសន្នមានចំនួន៤ ទីតាំង
- កសាងសាលាខេត្ត និងតំបន់រដ្ឋបាលថ្មីស្ថិតនៅក្នុងឃុំរកាខ្ពស់
- រៀបចំតំបន់កសិទេសចរណ៍ និងតំបន់ទេសចរណ៍នានាក្នុងក្រុង
- គ្រោងរៀបចំផ្សារធំមួយស្ថិតនៅភូមិទួលក្រសាំង សម្រាប់ដោះដូរទំនិញរបស់ប្រជាពលរដ្ឋ
- សាងសង់អាងប្រព្រឹត្តកម្មចំនួន ៥ទីតាំងស្ថិតនៅសង្កាត់ព្រែកសំរោង ឃុំសិត្បូ និងឃុំរកាខ្ពស់
- សាងសង់មជ្ឈមណ្ឌលកែប្រែបន្សាបគ្រឿងញៀនជាប់បឹងត្នោត ក្នុងភូមិសិត្បូ សង្កាត់សិត្បូ
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- កសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅតាមសង្កាត់ព្រែកសំរោង ឃុំសិត្បូ និងឃុំរកាខ្ពស់
- គ្រោងរៀបចំចំណតរថយន្តក្រុងសាធារណៈចំនួន៤ ទីតាំងដូចជា៖

- ទីតាំងទី១ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ
- ទីតាំងទី២ ស្ថិតនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ
- ទីតាំងទី៣ ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់
- ទីតាំងទី៤ ស្ថិតនៅភូមិព្រែកត្រែង សង្កាត់សិត្បូ។

– កែលម្អ និងស្តារ ផ្លូវជាតិលេខ២១ ផ្លូវក្រវាត់រាជធានីភ្នំពេញ និងផ្លូវក្រវាត់ក្រុងតាខ្មៅ ចិញ្ចើមផ្លូវ បណ្តាញផ្លូវ លម្អសាធារណៈ កំណត់ប្រភេទ និងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងតាខ្មៅស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយផាសុកភាព សម្រាប់មនុស្សទាំងអស់គ្នា

– កែលម្អ និងថែទាំបណ្តាញផ្លូវដែលមានស្រាប់ក្នុងក្រុងអមដោយដើមរុក្ខជាតិនិងផ្កា និងដើមឈើលម្អអមសងខាងផ្លូវ និងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង និងបង្គោលភ្លើងភ្លឺចម្រុះពណ៌

– អប់រំ និងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ

– ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ

– ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

**៥.៤.៣-ការអនុវត្តរយៈពេលវែង**

– លើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ និងប្រើប្រាស់រថយន្តដើរដោយអាគុយ

– សាងសង់ស្ពាន និងស្ពានអាកាសថ្មើរជើង មានចំនួន៧ ទីតាំង ដូចជាៈ

- ទីតាំងទី១ ពីរង្វង់មូលតាខ្មៅ ចម្ងាយប្រមាណ៤២ ម៉ែត្រ ស្របតាមផ្លូវជាតិលេខ២១ ស្ថិតនៅភូមិតាខ្មៅ២ សង្កាត់តាខ្មៅ
- ទីតាំងទី២ នៅតាមបណ្តោយនៃកំណាត់ផ្លូវជាតិលេខ២១ ចម្ងាយប្រមាណប្រមាណ ៤២៨ ម៉ែត្រ ពីចំណុចប្រសព្វផ្លូវជាតិលេខ២១នឹងផ្លូវលេខ១១៥ ស្ថិតនៅភូមិថ្មី១ សង្កាត់តាខ្មៅ

- ទីតាំងទី៣ នៅតាមបណ្តោយនៃកំណាត់ផ្លូវជាតិលេខ២ ចាប់ពីរង្វង់មូលព្រះនរាយណ៍ ចម្ងាយប្រមាណ១៩៥ ម៉ែត្រ ស្ថិតនៅភូមិដើមមៀន សង្កាត់ដើមមៀន
- ទីតាំងទី៤ នៅតាមបណ្តោយកំណាត់ផ្លូវជាតិលេខ២ ពីរង្វង់មូលតាខ្មៅ ចម្ងាយប្រមាណ ១៦៧៦ ម៉ែត្រ ស្ថិតនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី
- ទីតាំងទី៥ នៅតាមបណ្តោយកំណាត់ផ្លូវជាតិលេខ២ នៃចំណុចប្រសព្វរវាងផ្លូវជាតិលេខ២ នឹងផ្លូវលេខ១១៥ ចម្ងាយប្រមាណ៣១៣ ម៉ែត្រ ស្ថិតនៅជាប់ព្រំប្រទល់រវាងភូមិបត្តជីនឹងភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ
- ទីតាំងទី៦ នៅតាមបណ្តោយកំណាត់ផ្លូវជាតិលេខ២ ចម្ងាយប្រមាណ៦២ ម៉ែត្រ ពីចំណុចប្រសព្វផ្លូវជាតិលេខ២ នឹងផ្លូវក្រវាត់រាជធានីភ្នំពេញ
- ទីតាំងទី៧ នៅតាមបណ្តោយកំណាត់ផ្លូវលេខ១១៥ មានចម្ងាយប្រមាណ៩៤៥ ម៉ែត្រ ពីចំណុចប្រសព្វផ្លូវជាតិលេខ២ នឹងផ្លូវលេខ១១៥ ស្ថិតនៅជាប់ព្រំប្រទល់ភូមិខ្ពបនឹងភូមិព្រែករាំង សង្កាត់កំពង់សំណាញ់

– គ្រោងរៀបចំបណ្ណាល័យចំនួន ៣ ទីតាំងដូចជា៖
  - ទីតាំងទី១ ស្ថិតនៅភូមិតាខ្មៅ១ សង្កាត់តាខ្មៅ
  - ទីតាំងទី២ ស្ថិតនៅភូមិព្រែកថ្មី១ សង្កាត់តាខ្មៅ
  - ទីតាំងទី៣ ស្ថិតនៅភូមិកោះគរ ឃុំរកាខ្ពស់។

– ការពារ និងថែរក្សាផ្លូវ ដីចំណីផ្លូវ

– រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការគ្រប់គ្រង ក្នុងការការពារប្រភពផ្គត់ផ្គង់ ទឹកបណ្តាលមកពីការអភិវឌ្ឍ ក្រុង

– ចំពោះសំណង់បណ្តោះអាសន្នតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ នៅតាមដងផ្លូវសាធារណៈ និងការតាំងទីលំនៅ ត្រូវបន្តដោះស្រាយតាមសារាចរលេខ០៣ ស.រ.ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមទីក្រុង និងទីប្រជុំជន

– ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីសាធារណៈ និងឯកជនរបស់រដ្ឋ ជាពិសេសនៅតាមមាត់ទន្លេបាសាក់ មាត់ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ នៅតាមដងផ្លូវសាធារណៈ និងមាត់បឹង

– សិក្សាពីលទ្ធភាពនៃការធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានលំនៅឋាន និងប្រជាពលរដ្ឋរស់នៅក្នុងសំណង់បណ្តោះអាសន្ន

- ចំពោះគម្រោងពង្រីកក្រុង ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជា៖ បណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងទឹកភ្លៀង ប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗ ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ដូចជា តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លម្ហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍពេលអនាគត។ល។ ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍន៍បៃតង សំដៅធ្វើឱ្យទីក្រុងក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព
- គ្រោងគម្រោងចក្ខុវិស័យ សម្រាប់ផ្លូវរថភ្លើងទូទៅ និងរថភ្លើងអាកាស។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការចូលរួមអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋ និងឯកជន
- ថវិកាដៃគូអភិវឌ្ឍន៍
- ថវិកាចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ៧.១- យន្តការ

យន្តការ ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្តាល មានក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋបាលខេត្តកណ្តាល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល។

### ៧.២- ច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត មានជាអាទិ៍៖ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

### ៧.៣-ភារកិច្ច នីតិវិធី គោលការណ៍

រដ្ឋបាលខេត្តកណ្តាល ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ជាសេនាធិការ មានភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តផែនការរៀបចំដែនដីនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គការ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ ផែនការវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់
- ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃនេះ រដ្ឋបាលខេត្តកណ្តាល ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការត្រូវធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីនេះ ក្នុងរយៈពេល៥ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែង សំដៅបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍សង្គមជាតិ
- រដ្ឋបាលខេត្តកណ្តាល ដែលមានរដ្ឋបាលក្រុងតាខ្មៅជាចំណុះ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្តាល។

គោលការណ៍នៃការត្រួតពិនិត្យ និងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃផលប៉ះពាល់សង្គម និងបរិស្ថាន ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដី ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយ ឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ត្រូវបានរៀបចំឡើងនិងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោល សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យនានា ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣០ គឺ “ក្រុងតាខ្មៅ ជាទីក្រុងពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ ដែលមានគុណភាពបរិស្ថាន និងការរស់នៅ

ប្រកបដោយសុខដុមរមនា តាមរយៈការរៀបចំ និងជំរុញទៅជា៖ ១).ទីក្រុងមានសកម្មភាពពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគល្អប្រសើរ ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ២).ទីក្រុងអភិវឌ្ឍន៍ឧស្សាហកម្មទំនើប សិប្បកម្ម និងសហគ្រាសខ្នាតតូចនិងមធ្យម ដោយមានការទាក់ទាញការវិនិយោគ ធានាបាននូវកំណើនសេដ្ឋកិច្ច និងកំណើនការងារ ៣).ទីក្រុងទេសចរណ៍ដែលមានគុណភាព សេវាកម្ម ធានាបាននូវភាពទាក់ទាញ និងការចាប់អារម្មណ៍ខ្ពស់ពីភ្ញៀវជាតិ និងអន្តរជាតិ ៤).ទីក្រុងប្រកបដោយគុណភាពបរិស្ថាន និងការរស់នៅប្រកបដោយសុខដុមរមនា និង ៥).ទីក្រុងអភិរក្សធនធានធម្មជាតិ ទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ បឹងធម្មជាតិ និងតំបន់ធនធានទឹកជាច្រើន" និងដើម្បីរួមចំណែកអភិវឌ្ឍនិងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន ផ្នែកឯកជន និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្តតាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ថ្នាក់ក្រុង និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវជំរុញការផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់នូវប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**៩-អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ អនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់ រដ្ឋបាលក្រុង រដ្ឋបាលខេត្ត ត្រូវយកចិត្តទុកដាក់៖

ទី១.អនុវត្តបទប្បញ្ញត្តិប្រើប្រាស់ដីតាមតំបន់នីមួយៗ និងត្រូវបន្តរៀបចំផែនការប្រើប្រាស់ដី ព្រមទាំងប្លង់លម្អិតនគរូបនីយកម្ម ចុះបញ្ជីដីធ្លីស្របតាមគម្រោងប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានាក្នុងការគ្រប់គ្រងដី ប្រើប្រាស់ដី និងសំណង់ឱ្យមានប្រសិទ្ធភាព។

ទី២.រៀបចំផែនការសកម្មភាព និងគម្រោងវិនិយោគតាមលំដាប់អាទិភាព ដើម្បីធ្វើការផ្សព្វផ្សាយកៀងគរដៃគូអភិវឌ្ឍន៍ និងអ្នកវិនិយោគទុន ស្របតាមច្បាប់វិនិយោគ និងបទដ្ឋានគតិយុត្តជាធរមាន។

ទី៣.លើកកម្ពស់សមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ក្រុង និងថ្នាក់ខេត្ត ដើម្បីធានាការគ្រប់គ្រង និងអភិបាលកិច្ចល្អ។

ទី៤.តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងរៀបចំធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដី ដើម្បីស្នើសុំការអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

ទី៥.តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសក្នុងការសាងសង់ការប្រើប្រាស់ និងអភិវឌ្ឍន៍ដីធ្លីដែលមិនគោរពតាមប្លង់គោល ផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

ទី៦.រៀបចំកញ្ចប់ថវិកាថ្នាក់ខេត្ត និងថ្នាក់ក្រុង សម្រាប់អនុវត្តគម្រោងផែនការជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាសាធារណជន និងលម្ហសាធារណៈ។

ទី៧.ស្នើសុំកិច្ចសហការ និងគាំទ្រពីគ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ដើម្បីធានាការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅឱ្យមានប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មល្អប្រសើរ។

## សន្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំង តំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌ ថ្នាក់ ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់ រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដីនិងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍ និងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាល និងសេវាសាធារណៈ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមមហាវិថីផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់ បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រកសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួមមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួម

ទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមនីយដ្ឋាន ឬមជ្ឈមណ្ឌលកំសាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

## ឯកសារឧបសម្ព័ន្ធ

- របាយការណ៍បច្ចេកទេសលម្អិតប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ
- ផែនទីផែនការប្រើប្រាស់ដីលម្អិតក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០
- ផែនទីតំបន់អាចសាងសង់បាន និងកម្រិតការសាងសង់ក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងលម្ហបៃតងក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីលម្អិតក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣០

## Detail Land Use Master Plan of Takhmau City, 2030



# ផែនទីតំបន់អាចសាងសង់បាន និងកម្រិតការសាងសង់ ក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣០

## Buildable Area and Control Area Map of Takhmau City, 2030

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ










គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងតាខ្មៅ

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ និងលំហបៃតង ក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣០

# Tourism and Green Space Development Map in Takhmau City, 2030

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ












**ប្រភពទិន្នន័យ៖**

- ដោយផែនទីនេះ ត្រូវបានគូសដោយផ្អែកលើរូបថតពីលើអាកាស ដោយការអង្កេតដោយផ្ទាល់នៅទីតាំងជាក់ស្តែងនិងប្រើប្រាស់ឧបករណ៍ GPS
- ផែនទីនេះត្រូវបានរៀបចំឡើងដោយមន្ទីរ ស.ន.ស.ស ខេត្តកណ្ដាល និងការិយាល័យ ស.ន.ស.ភ ក្រុងតាខ្មៅ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។
- ព្រំប្រទល់ឃុំ-សង្កាត់ ស្រុក-ក្រុង ខេត្ត៖ ទិន្នន័យ JICA 2002
- ព្រំប្រទល់ឃុំ-សង្កាត់ ស្រុក-ក្រុង ទីប្រជុំជន និងភូមិ មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។

**មាត្រដ្ឋានផែនទី**

មាត្រដ្ឋាន ១ : ៦៥ ០០០

0 0.5 1 2 3 4 គីឡូម៉ែត្រ

គាំទ្របច្ចេកទេសដោយ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

សំគាល់៖ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល ...

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងតាខ្មៅ ...

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ក្រុងតាខ្មៅ សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣០

## Technical Infrastructure Development Map of Takhmau City, 2030

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ






គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងតាខ្មៅ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចក្ខុវិស័យឆ្នាំ២០៣០

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ...០០៦ សសរ...ចុះថ្ងៃ...............ខែ...............ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី...០៥...ខែ...កក្កដា...ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ












### ប្រភពនិន្នន័យ៖

- ផែនទីនេះ ត្រូវបានគូសដោយផ្អែកលើរូបថតពីលើអាកាស ដោយការផ្ទៀងផ្ទាត់ផ្ទាល់នៅទីតាំងជាក់ស្ដែងនិងប្រើប្រាស់ឧបករណ៍GPS
- ផែនទីនេះត្រូវបានរៀបចំឡើងដោយមន្ទីរ ដ.ន.ស.ស ខេត្តកណ្ដាល និងការិយាល័យ ដ.ន.ស.ភ ក្រុងតាខ្មៅ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។
- ព្រំប្រទល់ឃុំ-សង្កាត់ ស្រុក-ក្រុង ខេត្ត៖ ទិន្នន័យ JICA 2002
- ព្រំប្រទល់ឃុំ-សង្កាត់ ស្រុក-ក្រុង ទីប្រជុំជន និងភូមិ មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។

### មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១ : ៥០ ០០០

0 0.5 1 2 3 4 គីឡូម៉ែត្រ

ជា សុផារ៉ា

បណ្ឌិត ប៉ែន-សុផល

ម៉ៅ ភិរុណ

នូ-សុវណ្ណារ៉ា